# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការក្រសួងយុត្តិធម៌
លេខ ១៩៤ ពគ.បជ-៩៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**ព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យ**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីការចាប់ឃុំខ្លួនឬបង្ខាំងមនុស្សដោយខុសច្បាប់ ។

**យោង:** របាយការណ៍ត្រួតពិនិត្យពន្ធនាគារលេខ ៥៩១ អក-៩៥ ចុះថ្ងៃទី១២-០១-៩៥ របស់ព្រះរាជអាជ្ញាអមតុលាការខេត្តបន្ទាយមានជ័យ ។

ខ្ញុំសូមជម្រាបលោកថា មានតែចៅក្រមស៊ើបអង្កេតទេដែលមានសិទ្ធិសម្រេចឃុំខ្លួនជនដែលប្រព្រឹត្តបទល្មើសមិនជាក់ស្ដែងតាមមាត្រា ១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ក្នុងករណីមានជនណាចាប់ឃុំខ្លួនឬបង្ខាំងខ្លួនមនុស្សដោយគ្មានដីកាចាប់ខ្លួនពីអាជ្ញាធរតុលាការទេ ជននោះត្រូវមានទោសពីបទបង្ខាំងមនុស្សដោយខុសច្បាប់ដែលមានចែងត្រង់មាត្រា ៣៥ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចំណែកអ្នកទទួលទុកជនណាដែលចាប់ឃុំខ្លួនឬបង្ខាំងខ្លួនដោយគ្មានបទបញ្ជាពីអាជ្ញាធរតុលាការនោះក៏ត្រូវមានទោសពីបទសមគំនិតបង្ខាំងមនុស្សដោយខុសច្បាប់ដែរ គឺត្រូវផ្ដន្ទាទោសតាមមាត្រា ៦៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ដូច្នេះចាប់ពីថ្ងៃនេះតទៅបើមានអំពើនេះកើតឡើង ព្រះរាជអាជ្ញាខេត្តបន្ទាយមានជ័យ ធ្វើការចោទប្រកាន់ជាបន្ទាន់ទៅលើអ្នកប្រព្រឹត្តអំពើបង្ខាំងមនុស្សដោយខុសច្បាប់ និងអ្នកសមគំនិត ហើយអនុវត្តទៅតាមបញ្ញត្តិមាត្រាទី២២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

អាស្រ័យហេតុនេះ សូមលោកអនុវត្តតាមការណែនាំនេះឱ្យបានហ្មត់ចត់និងត្រឹមត្រូវបំផុតដើម្បីកុំឱ្យខុសឆ្គងក្នុងការអនុវត្តច្បាប់ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៩៦

**រដ្ឋមន្ត្រី**

**ចែមស្នួន**

ចម្លងជូន

-ព្រះរាជអាជ្ញាអមតុលាការខេត្ត.ក្រុង
-ឯឧត្តមអភិបាលខេត្ត-ក្រុង
-លោកស្នងការនគរបាលខេត្ត ក្រុង
-លោកប្រធានពន្ធនាគារខេត្ត ក្រុង
-ដើម្បីជ្រាបនិងអនុវត្ត